ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៥៧ សប្តាហ៍ទី១ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃលក់

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៥-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ម៉ាក អេដវ៉ាត ហាគប៉ុន ខាវ៉ផនធ័រ (MARK EDWARD CARPENTER) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស កើតនៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ៥៤៣៩

២៥-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី ដាន់ ដាយអិនមេ (DUNNE DIANE MAY) ជនជាតិអូស្ត្រាលី សញ្ជាតិ អូស្ត្រាលី កើតនៅក្រុងធើត ប្រទេសអូស្ត្រាលី ៥៤៤០

២៣-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៤៣ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម, លោក, លោកឧកញ៉ា និង លោកស្រីឧកញ៉ា ចំនួន ០៥ រូប ៥៤៤១

២៤-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៤៥ ស្តីពីការតែងតាំង ឯកឧត្តម អ៊ុំ ដារ៉ាវុធ ទីប្រឹក្សា អមព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋមន្ត្រី ៥៤៤២

២៤-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៤៦ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូន នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៥៤៤៣

២៥-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៤៧ ស្តីពីការបញ្ចប់តំណែងមេធាវីរាជរដ្ឋាភិបាល ដែលបានទទួលការតែងតាំងមុនថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ និង តែងតាំងមេធាវី រាជរដ្ឋាភិបាល ចំនួន ០៣ រូប ៥៤៤៤

២៥-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៤៩ ស្តីពីការតម្លើងឯកឧត្តម ឈា ហន ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងព្រះ បរមរាជវាំង ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៩ តទៅ ៥៤៤៥

២៥-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥០ ស្តីពីការតែងតាំង លោក ឆាង គួង និង លោកស្រី ម៉េង ចាន់បុប្ផា ជា ឧកញ៉ា ៥៤៤៦

២៥-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥១ ស្តីពីការតែងតាំង លោក សេង សារី ជា ឧកញ៉ា ៥៤៤៧

២៧-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥២ ស្ដីពីការតែងតាំងឯកឧត្ដម អ៊ុំ ម៉ារ៉ា ឋានន្តរស័ក្ដិ ឧត្ដមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជាអភិបាល នៃគណៈអភិបាលខេត្ត ព្រះវិហារ ៥៤៤៨

២៨-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៣ ស្ដីពីការតម្លើងឋានន្តរស័ក្ដិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៦ រូប ៥៤៤៩

២៨-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៤ ស្ដីពីការតម្លើងឋានន្តរស័ក្ដិជូនឯកឧត្ដម ខៀវ ច័ន្ទប៊ុនធឿន ពីឋានន្តរស័ក្ដិ វរមន្ត្រីថ្នាក់លេខ ៣ ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៣ នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៥៤៥០

២៩-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៥ ស្ដីពីការប្រោសព្រះរាជទាន ចំពោះសព ឯកឧត្ដម ព្រាប គាន់ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ជាកិច្ចបច្ឆាមរណៈ ៥៤៥១

២៩-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៦ ស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០៣ រូប ៥៤៥២

២៩-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៧ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌ ពិភពលោក ហៅកាត់ថា គ.ជ.ប.ព. ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការជាតិយូណេស្កូ កម្ពុជា ដើម្បីការពារ និង អភិវឌ្ឍសម្បត្តិធម្មជាតិ និង សម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបី នៃព្រះរាជាណាចក្រកម្ពុជា ៥៤៥៣

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២៧-៧-២០០៩ -អនុក្រឹត្យលេខ ១០៦ អនក្រ.បក ស្ដីពីការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ ៥៤៥៦

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១០៧ អនក្រ.បក ស្ដីពីការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និង ប្រគល់ជូនជាកម្មសិទ្ធិដល់សកលវិទ្យាល័យកម្ពុជា ស្ថិតនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ៥៤៦៣

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥៤៦៦

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១០៩ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ជូនទីស្ដីការគណៈរដ្ឋមន្ត្រី ៥៤៦៨

ឝ

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១១០ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យស្តីពីការផ្ទេរសិទ្ធិ គ្រប់គ្រងចំការកៅស៊ូក្រែក ៥៤៧០

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១១១ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យស្តីពីការផ្ទេរសិទ្ធិ គ្រប់គ្រងចំការកៅស៊ូមេមត់ ៥៤៧២

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១១២ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ នៃក្រសួងធម្មការ និង សាសនា ៥៤៧៤

០១-៧-២០០៩ -អនុក្រឹត្យលេខ ១១៥២ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ អាណត្តិទី ៤ ៥៤៧៧

០១-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៣ អនក្រ.តត ស្តីពីការផ្ទេរមេដាយសហមេត្រី ៥៤៧៩

០១-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៤៨១

០១-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៥ អនក្រ.តត ស្តីពីការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិមន្ត្រីរាជការ ៥៤៨២

០២-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៤៩០

០២-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៤៩១

០២-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៨ អនក្រ.តត ស្តីពីការផ្ទេរមេដាយស្ថាបនាជាតិ ៥៤៩២

០២-៧-២០០៩ -អនុក្រឹត្យលេខ ១១៥៩ អនក្រ.តត ស្តីពីការផ្ទេរមេដាយសុវត្ថារា ៥៤៩៣

០២-៧-២០០៩ -អនុក្រឹត្យលេខ ១១៦០ អនក្រ.តត ស្តីពីការផ្ទេរមេដាយសហមេត្រី ៥៤៩៥

០២-៧-២០០៩ -អនុក្រឹត្យលេខ ១១៦១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៤៩៦

០៣-៧-២០០៩ -អនុក្រឹត្យលេខ ១១៦២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៥៤៩៧

០៣-៧-២០០៩ -អនុក្រឹត្យលេខ ១១៦៣ អនក្រ.តត ស្តីពីការផ្ទេរមេដាយការងារ ៥៥០១

០៣-៦-២០០៩ -អនុក្រឹត្យលេខ ១១៦៤ អនក្រ.តត ស្តីពីការផ្ទេរមេដាយមុនីសារាភ័ណ្ឌ ៥៥០២

០៣-៧-២០០៩ -អនុក្រឹត្យលេខ ១១៦៥ អនក្រ.តត ស្តីពីការផ្ទេរមេដាយការងារ ៥៥០៣

០៣-៧-២០០៩ -អនុក្រឹត្យលេខ ១១៦៦ អនក្រ.តត ស្តីពីការផ្ទេរមេដាយមុនីសារាភ័ណ្ឌ ៥៥០៨

០៣-៧-២០០៩ -អនុក្រឹត្យលេខ ១១៦៧ អនក្រ.តត ស្តីពីការផ្ទេរមេដាយការងារ ៥៥១០

២. សេចក្ដីសម្រេច

២៨-៧-២០០៩ -សេចក្ដីសម្រេចលេខ ៤៧ សសរ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំ និង ជំរុញការអនុវត្តយុទ្ធនាការឃោសនា ផ្សព្វផ្សាយទេសចរណ៍កម្ពុជា " កម្ពុជា : ព្រះរាជាណាចក្រ អច្ឆរិយៈ " "CAMBODIA-Kingdom of Wonder" និង ចលនាប្រឡងប្រណាំង " ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ " ៥៥១២

III. ការងារបណ្ដាក្រសួង

១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-៧-២០០៩ -ប្រកាសលេខ ៦២០ សហវ.ប្រក.គរ ស្ដីពីការផ្ទេរការគ្រប់គ្រងទីស្នាក់ការគយ និង រដ្ឋាករ កែវផុស នៃសាខាគយ និង រដ្ឋាករខេត្តកោះកុង និង មន្ត្រីភ្នាក់ងាររាជការគយ និង រដ្ឋាករទាំងអស់នៃទីស្នាក់ការនេះ ពីសាខាគយ និង រដ្ឋាករខេត្តកោះកុង ឱ្យស្ថិតក្រោម ការគ្រប់គ្រងរបស់ សាខាគយ និង រដ្ឋាករខេត្តព្រះសីហនុ ៥៥២០

២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២៨-៧-២០០៩ -ប្រកាសលេខ ៣៦៩ ប្រក.កសក ស្ដីពីការបង្កើតតំបន់ព្រៃឈើសម្រាប់សិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រព្រៃឈើ " អូរគ្រៀង " ៥៥២២

៣០-៧-២០០៩ -ប្រកាសលេខ ៣៧២ ប្រក.កសក.ប ស្ដីពីការប្ដូរឈ្មោះការិយាល័យកសិកម្មស្រុកក្រចេះ ទៅជាការិយាល័យកសិកម្មស្រុកចិត្របុរី និង ការបង្កើតការិយាល័យកសិកម្មក្រុងក្រចេះ ចំណុះ មន្ទីរកសិកម្មខេត្តក្រចេះ ៥៥២៥

៣. ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៨៩៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប៊ីអេចខេ ព្រៃម៉ៀ គ្រុប ៥៥២៧

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៨៩៥ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អង្គរ អ៊ែន ៥៥២៩

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៨៩៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ពិជ័យគុមារ-គាគា-រិទ្ធិ អ៊ីមផត-អិចផត & ឌីវេឡុបមេន ៥៥៣១

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៨៩៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហាង សឺង គ្រុប គ្រេឌីង ខូ អិលធីឌី ៥៥៣៣

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៨៩៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្វ្រី ម៉ាស (ខេមបូឌា) ៥៥៣៥

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩០០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ីស្ត ហ្វ៊ីស (ខេមបូឌា) សាយអិនស៍ & គ្រេដ ៥៥៣៧

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩០១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន រ៉ូយ៉ាល់ ដាយអឹមេន ៥៥៣៩

០៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩០៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន ឡៅគណាមីហ្ស-ហ្វ្រេនឆ៍ វ៉ៃតតល ហ៊្វីដ
យ៉ាញ្ញ ស្កុត ខមភេនី (ប្រូគួនតូ) ៥៥៤១

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩១២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេមើរីល អាយឡែន ៥៥៤២

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩១៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប៊ី.ខេ.ធី.អេស អេនធើប្រាយស៍ ភីធីអ៊ី អិលធីឌី ៥៥៤៤

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩១៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ីស៊ឺរ (ខេមបូឌា) ៥៥៤៦

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ម៉ាក អេដវ៉ាត ហាតថុន ខាភែនធ័រ (MARK EDWARD HATTON CARPENTER) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស កើតថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៦៣ នៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល.០៩០៦.៦៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

លេខៈ ៦៣៦.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ដាន់ ដាយអិនមេ** (DUNNE DIANE MAY) ជនជាតិអូស្ត្រាលី សញ្ជាតិអូស្ត្រាលី កើតថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៥៨ នៅក្រុងផើត ប្រទេសអូស្ត្រាលី ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៦៣៧ ច.ល

ដើម្បីចម្លងចែក

ភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្តកេន

៣រ.ល.០៩០៦.៦៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៧០៩/៧៤៣

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

១- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

- លោកស្រីឧកញ៉ា គិត ហុងយី

២- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

- ឯកឧត្តម បែនសុន សមិយ
- លោកឧកញ៉ា ភូ នុនហេង
- លោកឧកញ៉ា ម៉ៀង សុក

៣- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

- លោក ទេង ជួ

៣១ល.០៩០៧.៧៨៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩

លេខៈ ៧០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញៈថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៤៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង ឯកឧត្ដម អ៊ុំ ដារ៉ាវុធ
ទីប្រឹក្សាអមព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ
មានឋានៈស្មើ រដ្ឋមន្ត្រី

នរោត្តម សីហមុនី

៣៤៧.០៩០៧.៧៥៦
បានប្រថាប់ព្រះរាជលញ្ឆករហើយ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខៈ ១០០/០៩ រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩
សម្ដេចចៅហ្វាវាំង កងសឹង អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គង់ សំអុល

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៧០៩/៧៤៦

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូន នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ឯក ខ៊ែត ចាន់ថុន អត្តលេខ ០១២០៧៨

២-វរសេនីយ៍ឯក មាស ចែ អត្តលេខ ០០៥០៦១

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៦៩៥.ច.ល

បានយកទៅ ...

ចម្លងចេញ

៣រល.០៩០៧. ៧៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ប្រធាន ...

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានបញ្ចប់តំណែងមេធាវីរាជរដ្ឋាភិបាល ដែលបានទទួលការតែងតាំងមុនថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ និងតែងតាំងមេធាវីរាជរដ្ឋាភិបាល ដូចខាងក្រោម :

១-ឯកឧត្តម ឆាំង ចន្ទតារា ជាមេធាវីរាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម សួន ចាន់ថន ជាមេធាវីរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ

៣-ឯកឧត្តម ជួន ឈឿន ជាមេធាវីរាជរដ្ឋាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.រ.ល.០៩០៧.៧៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៩

លេខ: ៦៩៣ ច.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៩
[illegible]

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៧០៩/៧៤៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្រមខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងព្រះរាជក្រឹត្យលេខ នស/រកត /០៦០៧/២១៦ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឯកឧត្តម ឈា ហាន ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងព្រះបរមរាជវាំង ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩ តទៅ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៧៦០ ច.ល

៣រល.០៩០៧.៧៦០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

១-លោក ឆាយ គួង

២-លោកស្រី ម៉េង ចាន់បុប្ផា

ជា

ឧកញ៉ា

៣រល. ០៩០៧. ៧៦១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៩

លេខៈ ៧០៤ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩
[illegible]រាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាសិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក សេង សារី

ជា

ឧកញ៉ា

ចរល.០៩០៧.៧៦២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៩

លេខ: ៧០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម អ៊ុំ ម៉ារ៉ា ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជា **អភិបាល** នៃគណៈអភិបាលខេត្ត ព្រះវិហារ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩

៣៩ល.០៩០៧.៧៦៣

លេខ: ៦៩៩. ច.ល
ជំរាបជូនចំពោះ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនភេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ទោ :

១-លោកឧត្តមសេនីយ៍ត្រី ចេន ចាន់តុង អត្តលេខ ០១៦១

ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-លោកវរសេនីយ៍ឯក ពេជ្រ យ៉ុន អត្តលេខ ០៦៧៣
២-លោកវរសេនីយ៍ឯក ធន់ ប៊ុនសយ អត្តលេខ ០២៨០
៣-លោកវរសេនីយ៍ឯក យាង វ៉ាន់នី អត្តលេខ ០៥៨៤
៤-លោកវរសេនីយ៍ឯក ណុប ផន អត្តលេខ ០៧២៦
៥-លោកវរសេនីយ៍ឯក ហម វ៉ាន់ថា អត្តលេខ ០២១១៣ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤ល.០៩០៧.៧៦៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩

លេខ: ៧០៩ ច.ល
...ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៩
...អគ្គលេខាធិការរាជរដ្ឋាភិបាល
... ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្រមខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១៤០ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្តម **ខៀវ ច័ន្ទឫទ្ធិនធឿន** ពីឋានន្តរស័ក្តិ វរមន្ត្រីថ្នាក់លេខ ៣ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៧០៦ ច.ល

ចរល.០៩០៧.៧៦៥

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៩

ហត្ថលេខា: ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សពឯកឧត្តម ព្រាប តាន់

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ជាកិច្ចបច្ឆាមរណៈ

ចរល.០៩០៧.៧៦៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩

លេខ: ៩២០ ច.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៩
[illegible] រាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ដូចខាងក្រោម :

១-ឯកឧត្តម **ចុណ្ណ យុទ្ធា** ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ

២-ឯកឧត្តម **ទាំ ពិសី** ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឯកឧត្តម **ស៊្រុន ធីរិទ្ធ** ជាសមាជិកបម្រុង មានឋានៈស្មើអគ្គនាយក។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបាននូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩

រ.ល.០៩០៧.៧៦៧

លេខៈ ៧១១ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[signature]
សុខ ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៧

ស្តីពី
ការបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក ហៅកាត់ថា គ.ជ.ប.ព. ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការជាតិយូណេស្កូកម្ពុជា ដើម្បីការពារ និងអភិវឌ្ឍសម្បត្តិធម្មជាតិនិងសម្បត្តិវប្បធម៌ជាតិទាំងរូបីទាំងអរូបីក្នុងក្របខណ្ឌអន្តរជាតិ។

មាត្រា២.-

គ.ជ.ប.ព.មានសមាសភាពដូចខាងក្រោម ÷

- ឥស្សរជនជាន់ខ្ពស់មួយរូប ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

-តំណាងអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ

នៃប្រាសាទព្រះវិហារ សមាជិក

-តំណាងអាជ្ញាធរអប្សរា សមាជិក

-តំណាងគណៈកម្មការជាតិយូណេស្កូកម្ពុជា សមាជិក

-នាយកសារមន្ទីរជាតិភ្នំពេញ សមាជិក

-នាយកសារមន្ទីរព្រះនរោត្តម សីហនុ អង្គរ សមាជិក

សមាសភាពជាក់ស្តែងនៃគ.ជ.ប.ព.ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៣.-

គ.ជ.ប.ព.អាចមានឥស្សរជន ឬ អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនជាទីប្រឹក្សាជាន់ខ្ពស់ ឬជាទីប្រឹក្សា។

មាត្រា៤.-

គ.ជ.ប.ព.មានតួនាទី និងភារកិច្ចដូចតទៅ ÷

-តំណាងឱ្យព្រះរាជាណាចក្រកម្ពុជានៅក្នុងការប្រជុំស្របតាមលក្ខន្តិកៈឬការប្រជុំបច្ចេកទេសដែលទាក់ទងនឹងការអនុវត្តអនុសញ្ញាឆ្នាំ ១៩៧២ និងឆ្នាំ ២០០៣

-ពិនិត្យតាមដានការដាក់បញ្ចូលឬការវាយតម្លៃរបាយការណ៍ស្ថានភាពនៃការអភិរក្សសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបីដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោករួចហើយ

-ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអន្តរជាតិជាមួយគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោកនៃប្រទេសនានា និងការពារចំពោះមុខស្ថាប័នវប្បធម៌អន្តរជាតិ នូវជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបី

-អនុវត្តគ្រប់សកម្មភាពដើម្បីរំលេច និងលើកកម្ពស់រាល់តម្លៃជាសកល និងដោយឡែកនៃបេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ខ្មែរទាំងរូបី ទាំងអរូបីនៅទូទាំងពិភពលោក

-សហការជាមួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ដើម្បីជំរុញការងារអភិរក្សឱ្យមានប្រសិទ្ធភាពនិងការផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ

-រៀបចំផែនការសកម្មភាពស្តីពីការអភិរក្សសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបីដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោករួចហើយ និងការវាយតម្លៃសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ផ្សេងៗទៀត ដើម្បីស្នើចុះបញ្ជីបេតិកភណ្ឌពិភពលោក

ROYAUME DU CAMBODGE · LE ... ROYAL

-ធ្វើរបាយការណ៍អំពីបញ្ហាទាក់ទងនឹងបេតិកភណ្ឌពិភពលោក និងរបាយការណ៍ស្តីពីសកម្មភាពរបស់គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោកតាមការកំណត់ជូនរាជរដ្ឋាភិបាល

-បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ៥.-

គ.ជ.ប.ព.ត្រូវប្រជុំសាមញ្ញយ៉ាងតិច០៤(បួន) ដងក្នុងមួយឆ្នាំ និងប្រជុំវិសាមញ្ញតាមការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន។

គ.ជ.ប.ព.មានសិទ្ធិអញ្ជើញលេខាធិការអចិន្ត្រៃយ៍ផ្នែកវិទ្យាសាស្ត្រ នៃគណៈកម្មាធិការវប្បធម៌អន្តរជាតិសម្រាប់អង្គរ ប្រធានផ្នែកវប្បធម៌និងបេតិកភណ្ឌនៃការិយាល័យយូណេស្កូភ្នំពេញ ឥស្សរជន និងតំណាងក្រសួងពាក់ព័ន្ធមកចូលរួមប្រជុំរបស់ខ្លួន។

ប្រការ៦.-

គ.ជ.ប.ព.មានលេខាធិការដ្ឋាននៅគណៈកម្មការជាតិយូណេស្កូកម្ពុជា ដែលដឹកនាំដោយលេខាធិការ០១ (មួយ)រូប។ លេខាធិការដ្ឋាននេះអាចប្រើប្រាស់មន្ត្រីរបស់គណៈកម្មការជាតិយូណេស្កូកម្ពុជាតាមការចាំបាច់។

ប្រការ៧.-

គ.ជ.ប.ព.មានប្រភពធនធានថវិកាមកពី ÷

-ថវិកាជាតិក្នុងកញ្ចប់ថវិការបស់គណៈកម្មការជាតិយូណេស្កូកម្ពុជានៅក្នុងក្របខណ្ឌថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី

-ហិរញ្ញប្បទានសហប្រតិបត្តិការពីក្នុង និងក្រៅប្រទេសដែលផ្តល់ដោយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា។

ប្រការ៨.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៥

ន/រ.ក.០៧០៥.៧៤៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ:៧០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៥

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ិន ជិនគេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៦.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិមួយ ដែលមានឈ្មោះថា **កម្ពុជា អង្គរ អ៊ែរ (Cambodia Angkor Air Ltd.,)** សរសេរកាត់ជាភាសាខ្មែរ **"ក.អ.អ"** និងសរសេរកាត់ជាភាសាអង់គ្លេស **" CAAir "** ។

មាត្រា ២.-

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ជាក្រុមហ៊ុនចម្រុះ ដែលភាគីកម្ពុជាមានភាគហ៊ុនចំនួន ៥១ (ហាសិបមួយ) ភាគរយ និងភាគីក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាមមានភាគហ៊ុនចំនួន ៤៩ (សែសិបប្រាំបួន) ភាគរយ។ ក្នុងចំណែករបស់ភាគីកម្ពុជា រាជរដ្ឋាភិបាលមានភាគហ៊ុន ២៥ (ម្ភៃប្រាំ) ភាគរយ និងក្រុមហ៊ុនវិនិយោគកម្ពុជាមានភាគហ៊ុន ២៦ (ម្ភៃប្រាំមួយ) ភាគរយ ។

មាត្រា ៣.-

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិ ដូចតទៅ÷

- ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- អនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិនេះ
- លក្ខន្តិកៈក្រុមហ៊ុន។

មាត្រា ៤.-

ការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" មានគោលដៅ÷

- ធ្វើប្រតិបត្តិការអាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាស ទាំងក្នុងស្រុក និងក្រៅស្រុក
- ធ្វើប្រតិបត្តិការអាជីវកម្ម ដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនផ្លូវអាកាសស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង/ឬវិស័យផ្សេងទៀត ទៅតាមកិច្ចព្រមព្រៀងជាបន្តបន្ទាប់
- ផ្តល់សេវាកម្មគាំទ្រដល់ឧស្សាហកម្មអាកាសចរណ៍ ។

មាត្រា ៥.–

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវទទួលបានការលើកទឹកចិត្តផ្នែកពន្ធ ដូចតទៅ÷

- នៅពេលក្រុមហ៊ុនមិនទាន់បានប្រមូលទុនវិនិយោគមកវិញពីការធ្វើអាជីវកម្ម ពន្ធអាករទាំងអស់ជាបន្ទុករបស់រដ្ឋ លើកលែងតែពន្ធលើប្រាក់ចំណេញ និងពន្ធកាត់ទុក
- ក្រុមហ៊ុនត្រូវបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០៩ (ប្រាំបួន) ភាគរយ ក្រោយពីប្រតិបត្តិការអាជីវកម្មបានរយៈពេល ០៨ (ប្រាំបី) ឆ្នាំ
- ក្រុមហ៊ុនត្រូវបង់ពន្ធកាត់ទុកតាមអត្រា ០២ (ពីរ) ភាគរយ រហូតដល់ពេលដែលក្រុមហ៊ុនប្រមូលបានទុនវិនិយោគមកវិញ
- បន្ទាប់ពីបានប្រមូលទុនវិនិយោគមកវិញ ភាគីទាំងពីរនឹងត្រូវជួបចរចាគ្នា ដើម្បីពិនិត្យពីលទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដល់ក្រុមហ៊ុន។

មាត្រា ៦.–

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវទទួលបានការលើកទឹកចិត្តផ្សេងទៀត ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម។

ជំពូកទី២
ការដឹកនាំនិងការគ្រប់គ្រង

មាត្រា ៧.–

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ៨.–

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងពេញលេញ ដើម្បីបំពេញការងារក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ÷

- តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- អគ្គនាយកនៃក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា អង្គរ អ៊ែរ សមាជិក
- តំណាងក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម សមាជិក
- តំណាងក្រុមហ៊ុនវិនិយោគកម្ពុជា សមាជិក

សមាជិកក្រុមប្រឹក្សាភិបាល ដែលជាសមាសភាពមកពីស្ថាប័នរដ្ឋ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ០៣ (បី) ឆ្នាំ។ អាណត្តិនេះអាចបញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពដែលខ្លួនតំណាងឱ្យ។

មាត្រា ៩.-

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញតាមអាណត្តិ និងសិទ្ធិប្រទាន ដែលបានទទួលពីម្ចាស់ភាគហ៊ុន ដើម្បីសម្រេចក្នុងនាមក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ក្នុងការរៀបចំលិខិតស្នាម ឯកសារផ្សេងៗទាក់ទងនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ស្របតាមច្បាប់ជាធរមាន។

ក្រុមប្រឹក្សាភិបាលមានតួនាទីដូចខាងក្រោម ៖

- សម្រេចលើគម្រោងផែនការរបស់ក្រុមហ៊ុន
- វាយតម្លៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសម្រួលឱ្យបានស្របតាមសភាពការណ៍
- សម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ក្រុមហ៊ុន
- សម្រេចលើសំណើសមស្របរបស់អគ្គនាយក ទាក់ទងនឹងរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ព្រមទាំងលក្ខន្តិកៈ និងតារាងប្រាក់បៀវត្ស ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន
- សម្រេចលើកិច្ចសន្យា និងអនុសញ្ញា ដែលក្រុមហ៊ុនជាភាគីហត្ថលេខីស្របតាមលក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន
- បង្កើត បើក ឬបិទការិយាល័យ និងទីស្នាក់ការគ្រប់កន្លែងរបស់ក្រុមហ៊ុន តាមការវិនិច្ឆ័យរបស់ខ្លួន
- សម្រេចលើការប្រើប្រាស់ប្រាក់ចំណេញរបស់ក្រុមហ៊ុន ស្របតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន។

មាត្រា ១០.-

ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំរៀងរាល់ ០៣(បី)ខែម្តង។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិច ០៣ (បី)នាក់។ ក្នុងករណីមិនមានកូរ៉ុម ការប្រជុំត្រូវលើកទៅ ០៥ (ប្រាំ)ថ្ងៃក្រោយ ដើម្បីពិភាក្សាលើរបៀបវារៈដដែល។ កិច្ចប្រជុំលើកក្រោយនេះ ត្រូវមានសមាជិកយ៉ាងតិច ០៣ (បី)នាក់។ ក្នុងករណីដែលសមាជិកចូលរួមមានចំនួនមិនគ្រប់កូរ៉ុម ចំនួន ០៣(បី)ដងជាប់ៗគ្នា ប្រធានក្រុមប្រឹក្សាភិបាលត្រូវលើកយកបញ្ហាខាងលើ ទៅដាក់ជារបៀបវារៈក្នុងកិច្ចប្រជុំរបស់ម្ចាស់ភាគហ៊ុន ដើម្បីដោះស្រាយ។

របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច ១០ (ដប់)ថ្ងៃ មុនពេលបើកអង្គប្រជុំ។

មាត្រា ១១.-

កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវរៀបចំក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយការប្រជុំ ហើយត្រូវបញ្ជូនទៅក្រសួង ស្ថាប័ន ឬអង្គភាពអាណាព្យាបាល សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបាន មុនការប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ ។

កំណត់ហេតុប្រជុំនេះត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលតំណាងឱ្យភាគីក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម ។

មាត្រា ១២.-

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ឱ្យអគ្គនាយកនូវអំណាចចាំបាច់ទាំងឡាយ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំក្រុមហ៊ុនស្របតាមច្បាប់ ។

អគ្គនាយកមានភារកិច្ចដូចតទៅ÷

- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច និងចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនីមួយៗ និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ក្រុមហ៊ុន
- ដឹកនាំក្រុមហ៊ុន លើផ្នែករដ្ឋបាល បច្ចេកទេសអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ
- ជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងគ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ក្រុមហ៊ុន ដោយគោរពតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន លក្ខន្តិកៈបុគ្គលិក ឬច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីនៅក្រោមឱវាទស្របតាមលក្ខខណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- តំណាងឱ្យក្រុមហ៊ុន និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីមានការចោទប្រកាន់តវ៉ា ការពារក្តីឱ្យក្រុមហ៊ុន និងប្តឹងជំទាស់ផ្សេងៗ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនប្រគល់ជូន ។

មាត្រា ១៣.-

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវដឹកនាំគ្រប់គ្រងដោយអគ្គនាយក និងអគ្គនាយករងមួយចំនួន តាមការចាំបាច់ ។ អគ្គនាយកត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល តាមសំណើរបស់ភាគីក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម ។ អគ្គនាយករងត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល តាមសំណើរបស់ភាគីកម្ពុជាតាមរយៈអគ្គនាយក ។

មាត្រា ១៤.-

ការចុះ និងអនុវត្តកិច្ចសន្យាដោយក្រុមហ៊ុន ត្រូវគោរពតាមបែបបទ និងនីតិវិធី ដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ ព្រមទាំងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៣
ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៥.-

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវកាន់កាប់គណនេយ្យរបស់ខ្លួន ឱ្យស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ១៦.-

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសម្រាប់តម្រូវការរបស់ខ្លួន។

មាត្រា ១៧.-

ក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវបង់ប្រាក់ចំណូលចូលថវិការដ្ឋទៅតាមការកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម។

មាត្រា ១៨.-

ត្រូវបានដាក់ឱ្យនៅអមក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០ ២១ ២២ ២៣ ២៤ និងមាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា ១៩.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២០*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងប្រគល់ជូនជាកម្មសិទ្ធិដល់ សាកលវិទ្យាល័យកម្ពុជា ស្ថិតនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលអោយមានថ្នាក់ស្មើ អគ្គនាយកដ្ឋានការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មអោយទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណូមពររបស់ចាំបាច់ចំពោះមុខ

សម្រេច

មាត្រា ១.-

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតនូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ទំហំមួយរយដប់ប្រាំពីរហិកតា (១១៧ហិកតា) ស្ថិតនៅឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

A(៣៨៧៤៩៦ , ១៥០១១៨៤) B(៣៨៨១៦០ , ១៥០១២៤៧) C(៣៨៨១៨៨ , ១៥០០៦៨៦)
D(៣៨៧៣៩១ , ១៥០០៦៧៧) និង E(៣៨៧៣៦៩ , ១៥០០៥៧៧) F(៣៨៧២៨៤ , ១៥០០២១៤)
G(៣៨៧៣៧៧ , ១៥០០២១៤) H(៣៨៧២៦៧ , ១៥០០០៣២) I(៣៨៧៣៣៨ , ១៥០០០៣៥)
J(៣៨៧៣២៤ , ១៤៩៩៨៨២) K(៣៨៧៥៦៤ , ១៤៩៩៩០៥) L(៣៨៧៥៥៩ , ១៤៩៩៦៩៨)
M(៣៨៨១០៤ , ១៤៩៩៦៨៦) N(៣៨៨២៣៩ , ១៥០០១៤៥) O(៣៨៨៤៣៤ , ១៥០០០៩៦)
P(៣៨៨៥១៦ , ១៥០០៣០៩) Q(៣៨៨២១៧ , ១៥០០៤២៤) R(៣៨៨១៩៣ , ១៥០០៥៧៤) ។

មាត្រា ២.-

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

មាត្រា ៣.-

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ មួយរយដប់ប្រាំពីរហិកតា (១១៧ហិកតា) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មាត្រា ៤.-

ត្រូវបានប្រគល់អាណាត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ មួយរយដប់ប្រាំពីរហិកតា (១១៧ហិកតា) ដូចមានចែងក្នុង មាត្រា ១ នៃអនុក្រឹត្យនេះ ប្រគល់ជូនជាកម្មសិទ្ធិដល់សកលវិទ្យាល័យកម្ពុជា ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប អាជ្ញាធរអប្សរា និងសកលវិទ្យាល័យកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ១០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក. ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.៧០០ លានរៀល (មួយពាន់ប្រាំពីររយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម សម្រាប់ចំណាយប្រតិបត្តិការក្នុងឆមាសទី ២ ឆ្នាំ ២០០៩។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..១១៩..អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ជូនទីស្តីការគណៈរដ្ឋមន្ត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភះ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩

-យោងអនុក្រឹត្យលេខ ១៩ អនក្រ.បក.ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការផ្តល់ឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩

-យោងអនុក្រឹត្យលេខ ៥៧ អនក្រ.បក.ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៨ ស្តីពីការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៨

-យោងអនុក្រឹត្យលេខ ៨០ អនក្រ.បក.ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៨

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតផ្ទេរឥណទានថវិកាចំនួន១០.០០០លានរៀល (ដប់ពាន់លានរៀលគត់) ពីជំពូក០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភធន និងជំនួយសង្គម) របស់ទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ២០០៨ ។

មាត្រា២: ឥណទានថវិកាដូចមានក្នុងមាត្រា ១ ខាងលើត្រូវបានកត់ត្រាមកក្នុងខ្ទង់ចំណាយ ពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីចំណាយក្នុងកិច្ចការប្រាសាទព្រះវិហារ ។ ការបញ្ជាចំណាយនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាបេឡាករនៃឥណទានពិសេសនេះ ។

មាត្រា៤: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- កាលប្បវត្តិ -ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា២នៃអនុក្រឹត្យស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូក្រែក

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសម្ភារៈកសិកម្ម និងក្រុមហ៊ុនជលផល

-បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូក្រែក

-តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសម្ភារៈកសិកម្ម និងក្រុមហ៊ុនជលផល

សម្រេច

មាត្រាមួយ.-

មាត្រា២នៃអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូក្រែក ត្រូវបានកែសម្រួលដូចខាងក្រោម ÷

មាត្រា២ថ្មី.-

ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូក្រែក ទៅឱ្យក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី ជំនួសក្រុមហ៊ុនប្រស្ព៊ើរធី អេហ្គ្រីខលឈ័រ ដើម្បីបន្តគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ លក់ និងកិច្ចសន្យាជួលសម្រាប់ចំការកៅស៊ូក្រែក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនប្រស្ព៊ើរធី អេហ្គ្រីខលឈ័រ និងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាបន្ថែមទី១លើកិច្ចសន្យាទិញ លក់ និងកិច្ចសន្យាបន្ថែមទី១លើកិច្ចសន្យាជួល សម្រាប់សហគ្រាសចំការកៅស៊ូក្រែក ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី និងក្រុមហ៊ុនប្រស្ព៊ើរធី អេហ្គ្រីខលឈ័រ ។

មាត្រាពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រាបី.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានក្រុមហ៊ុនពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានគណៈកម្មាធិការជាតិអចីនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ

ក្រុមហ៊ុនសន្ធានកសិកម្ម និងក្រុមហ៊ុនជលផល

សុខ អាន

កន្លែងទទួល

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា បី
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា២នៃអនុក្រឹត្យស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូមេមត់

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសម្ភារៈកសិកម្ម និងក្រុមហ៊ុនជលផល

-បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូមេមត់

-តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសម្ភារៈកសិកម្ម និងក្រុមហ៊ុនជលផល

សម្រេច

មាត្រាមួយ.-

មាត្រា២នៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ ស្ដីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូមេមត់ ត្រូវបានកែសម្រួលដូចខាងក្រោម ÷

មាត្រា២ថ្មី.-

ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូមេមត់ ទៅឱ្យក្រុមហ៊ុនចំការកៅស៊ូមេមត់ ខូអិលធីឌី ជំនួសក្រុមហ៊ុនធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំកសិកម្ម និងអាហារ៉ែណ នីហារ៉ែណ ដើម្បីបន្តគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ លក់ និងកិច្ចសន្យាជួល សម្រាប់សហគ្រាសចំការកៅស៊ូមេមត់ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំកសិកម្ម និងអាហារ៉ែណ នីហារ៉ែណ និងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាបន្ថែមទី១លើកិច្ចសន្យាទិញ លក់ និងកិច្ចសន្យាបន្ថែមទី១លើកិច្ចសន្យាជួល សម្រាប់សហគ្រាសចំការកៅស៊ូមេមត់ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនចំការកៅស៊ូមេមត់ ខូអិលធីឌី និងក្រុមហ៊ុនធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំកសិកម្ម និងអាហារ៉ែណ នីហារ៉ែណ ។

មាត្រា៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានក្រុមហ៊ុនពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
និងជាប្រធានគណៈកម្មាធិការជាតិអចិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ
ក្រុមហ៊ុនសម្ភារៈកសិកម្ម និងក្រុមហ៊ុនជលផល

សុខ អាន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងធម្មការ និងសាសនា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១.-

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ចំណុះក្រសួងធម្មការ និងសាសនា បំពេញបន្ថែមឱ្យអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា។

មាត្រា២.-

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងដឹកនាំដោយប្រធាន១ (មួយ)រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

រចនាសម្ព័ន្ធ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។

មាត្រា៣.-

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី លើវិស័យធម្មការ និងសាសនា ជាមួយអង្គការជាតិ និងអន្តរជាតិ សមាគម ដៃគូអភិវឌ្ឍ និងបណ្តាប្រទេសជាមិត្ត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ សមាគម ដៃគូអភិវឌ្ឍ និងបណ្តាប្រទេសជាមិត្ត ដែលមានបំណងរួមចំណែកអភិវឌ្ឍលើវិស័យធម្មការ និងសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- តាមដាន និងវាយតម្លៃលើរាល់សកម្មភាព ដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈនៃការយោគយល់ ពិធីសារ និងកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ
- ទំនាក់ទំនងសម្របសម្រួលកិច្ចការអាស៊ាន លើវិស័យធម្មការ និងសាសនា
- ទំនាក់ទំនង និងសហការ ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការសម្របសម្រួលលើកិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យធម្មការ និងសាសនា
- រៀបចំសម្របសម្រួលបែបបទជូនគណៈប្រតិភូ កម្មសិក្សាការីជាតិ អន្តរជាតិ និងទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូរបស់ក្រសួង
- កសាង និងចងក្រងឯកសារសាសនាគ្រប់និកាយ ដែលមាននៅលើពិភពលោក

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួន និងលើកទិសដៅអាទិភាពចំពោះមុខតាមសភាពការណ៍នយោបាយអន្តរជាតិ ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាន១ (មួយ) រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ។

មាត្រា៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ដើម្បីសូមចុះហត្ថលេខា
រដ្ឋមន្ត្រី ក្រសួងធម្មការនិងសាសនា

មិន ឃិន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៥៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឱ្យស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស ម្រេ ច

មាត្រា ១ : តែងតាំងក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៤ ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **ម៉េង សក្តិធារ៉ា**	អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម តំណាងក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល	ប្រធាន
២-ឯកឧត្តម ឯក សុនចាន់	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	សមាជិក
៣-ឯកឧត្តម អ៊ីវ ខេង	អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

៤-ឯកឧត្តម ជូ វិជិត្ត	អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥-ឯកឧត្តម ម៉ាន់ ឈឿន	អភិបាលរងរាជធានីភ្នំពេញ តំណាងសាលារាជធានីភ្នំពេញ	សមាជិក
៦-លោក ហុង ស៊ីលីន	អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ តំណាងក្រសួងមហាផ្ទៃ	សមាជិក
៧-លោក ឡុង ណារ៉ូ	អគ្គនាយករង ទទួលបន្ទុកជំនួយការអគ្គនាយកលើការងារបច្ចេកទេស តំណាងនិយោជិតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	សមាជិក

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ ២០០៩ .

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

[illegible]

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនឥស្សរជន និង មន្ត្រីថៃ ចំនួន១០រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយស្ថាបនាកំណាត់ផ្លូវជាតិ លេខ៦៧ (អន្លង់វែង-សៀមរាប) ដូចមានរាយនាមខាងក្រោម :-

ក.មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :

-ឯកឧត្តម VIRAPHAND VACHARATHIT ឯកអគ្គរាជទូតវិសាមញ្ញ ពេញសមត្ថភាពថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា (Ambassador Extraordinary and Plenipotentiary, Royal Thai Embassy to the Kingdom of Cambodia .)

ខ.មេដាយសហមេត្រី ថ្នាក់ សេនា :

១-លោក ACKSIRI BURANASIRI ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជិតខាង នៃប្រទេសថៃ (President of NEDA (Neighboring country Economic Development cooperation Agency) of Thailand.)

២-លោក TEERASAK MONGKOLPOD អនុប្រធានជាន់ខ្ពស់ នៃទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជិតខាង នៃប្រទេសថៃ (Senior Vice President of NEDA of Thailand.)

៣-លោក AMNAT PROMMASUTRA នាយកប្រតិបត្តិជាន់ខ្ពស់ នៃទីប្រឹក្សាបច្ចេកទេស TEAM ប្រទេសថៃ (Senior Executive Director, TEAM Consultant of Thailand.)

៤-លោក SAMART THANADBHOCHANAMART ប្រធានចាត់ចែងគំរោង នៃទីប្រឹក្សាបច្ចេកទេស TEAM ប្រទេសថៃ (Project Manager, TEAM Consultant of Thailand)

គ-មេដឹកនាំសហមេត្រី ថ្នាក់ អស្សុមន្ត្រី :

១-លោក SUPHOTH SUBLOM អគ្គនាយក នៃនាយកដ្ឋាន ហាយវេ ប្រទេសថៃ (Director General, Department of Highway of Thailand.)

២-លោក SUNANT GLIENGPRADIT នាយកការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋាន ហាយវេ ប្រទេសថៃ (Director-Bureau of International Cooperation, Department of Highway of Thailand.)

៣-លោក THONGCHAI JINTANAWONGSE នាយកសាខា នៃនាយកដ្ឋានសិក្សាស្រាវជ្រាវនិងវាស់ស្ទង់ ប្រទេសថៃ (Director-Survey and Topography Branch, Department)

៤-លោក RATN SANTAANNOP អនុប្រធានប្រតិបត្តិ នៃក្រុមហ៊ុនសាធារណៈ ឆកាន់ឆាង ប្រទេសថៃ (Executive Vice President, Ck. Karnchang Public Company Limited.)

៥-លោក PAIRAT PROM-IN ប្រធានចាត់ចែង នៃក្រុមហ៊ុនសាធារណៈ ឆកាន់ឆាង ប្រទេសថៃ (Project Manager, Ck. Karnchang Public Company Limited.)

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៖

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៨៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣ រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

- លោក ទ័ត់ សំរុល មានឋានៈស្មើ អគ្គនាយករង
- លោក ម៉ាន ស៊ីណេត មានឋានៈស្មើ ប្រធាននាយកដ្ឋាន
- លោក ទោច ស៊ីធឿន មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម
- បានឃើញព្រះរាជក្រមលេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួង ព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និង ឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១ : តម្លើងថ្នាក់តាមវេនជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន គិតចាប់ពី ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៩ តទៅ ដូចមានរាយនាមខាងក្រោម :

ក្រសួងសាធារណការ និងដឹកជញ្ជូន				
១	មាស សឿន	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
២	សួន រុត្ថា	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៣	ទង់ សំអាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៤	ឈុន ម៉ុនតេង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៥	អ៊ឹង ជុនឈួរ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៦	ម៉ីន មាណវី	ស	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៧	ឥម សុត្ថារ	ស	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៨	មាស ម៉ូនីកា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល				
៩	ឃុន ច័រី	ស	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២

១០	ឈុន ឈាន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
១១	រស់ សារិន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
១២	ហូ ការដឹប	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
១៣	សាត សាធី	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
១៤	គឹម ឆូច	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
១៥	សុខ ឡេង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
១៦	សាត សមុទ្រ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
១៧	ប៊ុន ណារិទ្ធ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
១៨	យក់ ប៊ុនស៊ីន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
១៩	អ៊ុច បូរ៉ា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
២០	កែវ សុវត្ថិ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
២១	ប៉េង ណាវុធ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
ក្រសួងសុខាភិបាល				
២២	អ៊ុំ វិចិត្រ	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
២៣	ឌូ យិនស៊ុម	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
២៤	សោម សារ៉ែន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
២៥	ហ៊ុយ សុវ៉ាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
២៦	ជា គឹមឡុង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
២៧	លឹម ម៉ៃឆាង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
២៨	ប្រាក់ ពិសិដ្ឋរស្មី	ស	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
២៩	ម៉ៅ តាន់ស៊ាង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៣០	ជា ប៊ុនហេង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៣១	ហ៊ាង ពន្លៃ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៣២	មាន ឈីវុន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៣៣	គាត ភួង	ស	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៣៤	សយ គិរម្យ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៣៥	ឡាយ ហួន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៣៦	ស៊ុម ខេងខាំ	ស	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៣៧	ម៉ី សំបុះ	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅថ្នាក់លេខ ៩
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍				
៣៨	ញាណ ស្រស់	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២

៣៩	ម៉ែន ទ៉ុយ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៤០	គ្រី ឆេង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៤១	អៀង ស្រេង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
៤២	កែវ ទុន្សិន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
៤៣	ឈី សុខា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
៤៤	អ៊ុច សុខុម	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
៤៥	ចេត ប៊ុន្នា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
៤៦	ប៉ុក សុផាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
៤៧	លីម ឈៀង	ស	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
៤៨	ចែម សច្ចារ	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅថ្នាក់លេខ ៩
ក្រសួងព័ត៌មាន				
៤៩	តាក់ លីហួក	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៥០	ឌី សុខណាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៥១	នួច ឆដ្ឋា	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៥២	ស៊ូ នី	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៥៣	ឈិន យួន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៥៤	ចាន់ សារ៉ាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៥៥	ព្រំ ឈួង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៥៦	នួត ឈៀង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៥៧	នាក់ សារ៉ាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៥៨	គី ឡុង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៥៩	សោម សារុន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៦០	ទួន សុផល	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៦១	អ៊ុយ ធួន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៦២	រស់ ណារិទ្ធ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៦៣	អ៊ិន ឆាយ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៦៤	ជា សាវុធ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៦៥	លុក ប៊ុណ្ណារដ្ឋ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៦៦	ឈាន លាង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៦៧	ជ័យ ទុន្សី	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៦៨	គួច សារ៉េត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥

៦៩	ជ័យ សារផាន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៧០	គាត ឧណ្ណៈ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
៧១	ផុស សុវណ្ណ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
៧២	ពៅ គីមចំនួរឆ្ន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
៧៣	ឈឹម ផល	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
៧៤	ឈី ទ៊ាន់ឃុង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ				
៧៥	ជុក មុន្នី	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៧៦	ជួប សុផាន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៧៧	ខៀវ ចំនួម៉ុនចឿន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៧៨	ឌិន សុខឃួន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៧៩	ទៅ មូលម៉ុនចាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៨០	នូ សុវណ្ណា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
ក្រសួងផែនការ				
៨១	ទី ហៀង	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
៨២	កែវ សម្បត្តិ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៨៣	ខៀវ សារី	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៨៤	សេង សឿន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៨៥	សោម សេរីវុឌ្ឍន៍	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៨៦	ឡូ សុភាព	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៨៧	ហ៊ាង សៀកលី	ស	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៨៨	ហ៊ីង ចំនួម៉ុន្នា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៨៩	គង់ សុផាត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
៩០	ឆួន ចាវចៈ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៩១	សាង សម	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៩២	ដួង សារុន	ស	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
៩៣	សួន សុខឃីម	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
៩៤	ឃាស់ ម៉ុនថុន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
ក្រសួងពាណិជ្ជកម្ម				
៩៥	អ៊ុយ សុខអាត្ម	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២

៩៦	ម៉ី សារ៉ែន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៩៧	ទ៉ែត សុគិន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៩៨	ឃឹម សិរីវឌ្ឍ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
៩៩	ឡៀង សារ៉ាត់	ស	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១០០	វ៉ា រុតសាន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១០១	ឈីវ មិនចំនួ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
១០២	ប៊ុន សុវណ្ណ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
១០៣	ស៊ាង ផៃ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨

មាត្រា ២ ៖ តម្លើងថ្នាក់តាមវេនជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ គិតចាប់ពីថ្ងៃ ទី ១៣ ខែ មេសា ឆ្នាំ ២០០៩ តទៅ ដូចមាននាមខាងក្រោម ៖

១០៤	ឡេ ម៉ាយតៀង	ប	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៩	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨

មាត្រា ៣ ៖ ត្រូវបានតម្លើងថ្នាក់តាមកម្រិតសញ្ញាប័ត្រជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម ៖

ទីស្តីការគណៈរដ្ឋមន្ត្រី				
១០៥	សូ ត្រៃ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
១០៦	អ៊ិត ចាន់ឡុង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
១០៧	ស៊ឹម សាន	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
១០៨	ហេង សុខឃៀង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤
១០៩	ចាក់ សុខហៃ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១១០	វ័ន្ត ថិរៈ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១១១	ណូ សម្បត្តិ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១១២	ថោង សុជាតិ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅថ្នាក់លេខ ៦
១១៣	ហង្ស ឧត្តរី	ស	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
១១៤	កើត សេកាណូ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
ក្រសួងព្រះបរមរាជវាំង				
១១៥	ឆេង ហួត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ថ្នាក់លេខ ៣
១១៦	ណឹប ចាន់ស្មើ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ថ្នាក់លេខ ៤
១១៧	ឆាន ណុន	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ថ្នាក់លេខ ៩

១១៨	តាន់ ប៊ុក	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ថ្នាក់លេខ ៩
ក្រសួងធនធានទឹក និង ឧតុនិយម				
១១៩	ទ៊ី ឈីហួត	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
១២០	ជួន ចិត្តថុល	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅថ្នាក់លេខ ៥
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ				
១២១	សរ សាម៉ុឌី	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅថ្នាក់លេខ ៩
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ				
១២២	ឆាវ សារឿន	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅថ្នាក់លេខ ៩

មាត្រា ៤ : ត្រូវបានតម្លើងថ្នាក់តាមកម្រិតសញ្ញាប័ត្រជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម :

១២៣	អ៊ាត សោភា	ស	ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨
១២៤	សុខ ជា	ប	ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៨	ទៅថ្នាក់លេខ ៧
១២៥	ណី សំអុល	ប	ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៩	ទៅថ្នាក់លេខ ៨

មាត្រា ៥ : មន្ត្រីដែលត្រូវបានតម្លើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ៣ និងមាត្រា ៤ ខាងលើ ត្រូវបានរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាព ដដែល ។

មាត្រា ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ មាត្រា ២ មាត្រា ៣ និងមាត្រា ៤ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩ .

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៧ : អនក្រ.តត

អនុក្រឹត្យ

ស្តីពី

តែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

យោងតាមការចាំបាច់

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោកវរសេនីយ៍ឯក **ជា សំណាង** នាយរងការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាជំនួយការលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៥៧ . អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៥ នាក់ ដូចខាងក្រោម :

១- លោកវរសេនីយ៍ទោ **ណោក សាម៉ុន** អត្តលេខ ០៣៧៦៨
២- លោកវរសេនីយ៍ទោ **ជា អឿន** អត្តលេខ ០១៤៤៨
៣- លោកវរសេនីយ៍ទោ **សេង ភ្លោ** អត្តលេខ ២០៤៦៣
៤- លោកវរសេនីយ៍ទោ **ព្រិល ចាន់ថន** អត្តលេខ ០៤៩០២
៥- លោកវរសេនីយ៍ទោ **ឃុន រិទ្ធី** អត្តលេខ ០៥៨២៣ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ[illegible] ឆ្នាំ២០០៩ .

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៨ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមក្នុងការកសាងសមិទ្ធផល លើវិស័យព្រះពុទ្ធសាសនា អប់រំ សង្គមកិច្ច និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅក្នុងសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ឃុំទ្រាស ឃុំសារង្គ ស្រុកស្វាយចេក និង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-លោក **ឆេត សុវណ្ណដារ៉ា** សប្បុរសជន នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២៣.២០០ ដុល្លារ

២-លោកស្រី **គីម កញ្ញនា** នាយករងក្រុមហ៊ុនញ្ញេវត្ថុ នៃសាលាខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២០.០០០ ដុល្លារ

៣-លោក **ហ៊ុយ ឌុយ** និង ភរិយា សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.១៨១ ដុល្លារ

៤-លោក **ពូន សានិត** សប្បុរសជន នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.១៥០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-អ្នកស្រី **ជួន ចរិយា** សប្បុរសជន នៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ៥.០០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក **ជូ ដារិន** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ដែលបានចំណាយអស់ថវិកាចំនួន ១.៥៣១ ដុល្លារ

២-លោក **ចាប់ សាវ៉ាន់** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ដែលបានចំណាយអស់ថវិកាចំនួន ១.១៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

